ទស្សនាវដ្តី
សម្លេងខ្មែរនៅបរទេស

# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## អំពីពាក្យថាអាណាចក្រនិងពុទ្ធចក្រ

Website: www.hoksavann.org

ថ្ងៃទី២៨ វិច្ឆិកា ២០០៤

### ១- អំពីពាក្យថាអាណាចក្រ ៖

ពាក្យថា«អាណាចក្រ»កាត់ជាពីរបទ គឺអាណាមួយបទ និងចក្រមួយបទ ។ ពាក្យថា«អាណា»ជាភាសាបាលី, ភាសាសំស្ក្រឹតថា«អាជ្ញា» ប្រែថាអំណាច, ច្បាប់បញ្ញត្តិ, ការគ្រប់គ្រង, ការបង្គាប់បញ្ជា។ ពាក្យថា«ចក្រ» សរសេរជា«ចក្រ»ក៏បាន សរសេរជា«ចក្ក»ក៏បាន ប្រែថាការប្រព្រឹត្តទៅ ឬការអនុវត្តន៍ច្បាប់ ។ រួមពាក្យទាំងពីរ «អាណាចក្រ» ប្រែថា អំណាចនៃការគ្រប់គ្រងនៃប្រទេសនីមួយៗ ដែលប្រព្រឹត្តទៅដូចកង់រទេះដែលវិលទៅមុខ ។ បានដល់ច្បាប់សំរាប់ប្រទេស ដូចជាច្បាប់កំពូលរបស់រដ្ឋ គឺច្បាប់រដ្ឋធម្មនុញ្ញ ដែលទាំងប្រជាពលរដ្ឋ ទាំងអ្នករដ្ឋការ ត្រូវអនុវត្តទាំងអស់គ្នា ដើម្បីសុខសន្តិភាពនិងការចំរើនលូតលាស់នៃប្រទេសរបស់ខ្លួន ។

### ២- អំពីពាក្យថាពុទ្ធចក្រ ៖

ពាក្យថា«ពុទ្ធចក្រ»ប្រែថា ការប្រព្រឹត្តទៅធម៌របស់ព្រះពុទ្ធ ។ ដូចជាព្រះពុទ្ធសំដែងធម៌ទេសនាជាដំបូងប្រោសភិក្ខុ៥អង្គ ដែលហៅថាធម្មចក្កប្បវត្តនសូត្រ គឺព្រះសូត្រដែលព្រះអង្គបានប្រព្រឹត្តទៅហើយ គឺបានសំដែងហើយក្នុងលោក ។ ធម៌នោះបានដល់អរិយសច្ចៈ៤ មានទុក្ខសច្ចៈ ជាដើមដែលជាធម៌ចេញចាកទុក្ខៈ ហើយដែលគ្មានតាបសឥសីណារកឃើញនិងសំដែងឡើយ ។ មគ្គសច្ចៈ នៅក្នុងអរិយសច្ចៈ៤ គឺមគ្គប្រកបដោយអង្គ៨ បានដល់សីលសមាធិបញ្ញា ជាមាគ៌ាដ៏បរិសុទ្ធក្នុងដំណើរឆ្ពោះទៅរកសេចក្តីសុខសន្តិភាពនៃមនុស្សជាតិក្នុងសង្គម ជាពិសេសចំពោះសព្វសត្វទាំងអស់ក្នុងភពបី ដើម្បីរំដោះខ្លួនចេញចាកទុក្ខ មានជាតិទុក្ខជាដើម បានដល់ព្រះនិព្វាន ។

### ៣- ទំនាក់ទំនងផ្លូវអាណាចក្រនិងពុទ្ធចក្រ ៖

ចំពោះប្រទេសកម្ពុជា ផ្លូវអាណាចក្រត្រូវមានផ្លូវពុទ្ធចក្រដើរទៅជាមួយ ។ ព្រោះថា ជាច្រើនសតវត្សមកហើយ ព្រះពុទ្ធសាសនាជាមាគ៌ាដែលប្រជាពលរដ្ឋខ្មែរបានអនុវត្តតាម តែងបានទទួលសេចក្តីសុខសាន្ត ។ ប៉ុន្តែមានសម័យខ្លះ អ្នកដឹកនាំខ្មែរបានដើរខុសពីមាគ៌ារបស់ព្រះពុទ្ធ បានធ្វើឲ្យប្រជាពលរដ្ឋខ្មែរបែកសាមគ្គីគ្នា ឆ្លៀតឱកាសនេះបរទេសបានចូលមករំលោភឈ្លានពានប្រទេសកម្ពុជា រហូតទឹកដីរួមតូចដូចសព្វថ្ងៃ ។ ព្រះពុទ្ធសាសនាជាមាគ៌ាបង្រួបបង្រួមជាតិខ្មែរ ជាមូលដ្ឋាននៃអត្តសញ្ញាណជាតិខ្លួន ព្រោះព្រះពុទ្ធសាសនាបានបង្រៀនឲ្យមនុស្សស្រឡាញ់រាប់អានជាតិខ្លួននិងមនុស្សក្នុងសកលលោក ដោយព្រះធម៌ប្រៀបប្រដៅទាំងឡាយ មានមេត្តាករុណា ដែលមាននៅក្នុងព្រហ្មវិហារធម៌ជាដើម ។ ផ្លូវអាណាចក្របានដាក់អាជ្ញាឲ្យមនុស្សខ្លាចច្បាប់ កុំឲ្យប្រព្រឹត្តខុស ។ ឯផ្លូវពុទ្ធចក្របានបង្រៀនមនុស្សឲ្យខ្លាចកំហុសខ្លួនឯង ។ បានសេចក្តីថា កំហុសដែលគេបានប្រព្រឹត្ត ទោះបីគេពុំបានដឹងពុំបានឮក៏ដោយ ក៏ខ្លួនឯងដឹងឮខ្លួនឯង សៅហ្មងចិត្តខ្លួនឯង ទទួលទោសខ្លួនឯងរួចទៅហើយ ។ ផ្លូវពុទ្ធចក្រ ទុកដូចជាអ្នកកាច់ចង្កូតផ្លូវអាណាចក្រ គឺនាំកម្ពុជាឲ្យដើរទៅតាមផ្លូវសច្ចធម៌ យុត្តិធម៌ និងផ្លូវសន្តិភាព ។ ព្រះពុទ្ធសាសនាជាឱសថសំរាប់រំលត់ភ្លើងសង្គ្រាម ជំរុញឲ្យមានសីលធម៌ ដោយការមិនបៀតបៀនគ្នា ដែលជាប្រភពសន្តិភាពពិភពលោក ជាពិសេសប្រទេសកម្ពុជា។ ផ្លូវពុទ្ធចក្រជាជំនួយមួយសំខាន់ណាស់ សំរាប់ជួយឧបត្ថម្ភផ្លូវអាណាចក្រ។ ឧទាហរណ៍ ការបង្កើតប៉ូលិសទាហានដើម្បីរក្សាសន្តិសុខនិងរបៀបរៀបរយសណ្តាប់ធ្នាប់ក្នុងសង្គម ព្រោះមានមនុស្សបៀតបៀនគ្នា រំលោភលើគ្នា ចុះបើទាំងអស់គ្នាខ្លាចអំពើបាប ពុំប្រព្រឹត្តធ្វើអំពើទាំងនោះតាមផ្លូវពុទ្ធចក្រ នោះប៉ូលិសទាហានមិនជាការចាំបាច់ ដែលត្រូវបង្កើតឲ្យមានទេ ។ ផ្លូវអាណាចក្រ មនុស្សប្រព្រឹត្តរំលោភច្បាប់របស់ប្រទេសអាចរួចចាកទោស ដោយគ្រាន់តែបិទបាំងកុំឲ្យអ្នកណាដឹងឮ ដើម្បីចៀសវាងកុំឲ្យឡើងតុលាការកាត់ទោស ។ ប៉ុន្តែផ្លូវពុទ្ធចក្រវិញនឹងគេចពុំរួចឡើយ ព្រោះអ្នកសាងអំពើបាប នឹងទទួលដល់បាបក្នុងពេលណាមួយពុំខានឡើយ ទោះបីពេលនេះបិទបាំងបានមួយពេលក៏ដោយ ។ បើគេប្រតិបត្តិតាមផ្លូវពុទ្ធចក្រ គេនឹងពុំប្រព្រឹត្តរំលោភច្បាប់របស់ប្រទេសឡើយ ទោះបីអំពើនោះបើធ្វើទៅគ្មានអ្នកណាដឹងឮក៏ដោយ ។ អំពើផ្តាច់ការរបស់អ្នកកាន់អំណាចរដ្ឋក្នុងការរំលោភបៀតបៀន រហូតមានការកាប់សម្លាប់ប្រជាពលរដ្ឋរបស់ខ្លួនពុំកើតមានឡើយ បើគេគោរពតាមផ្លូវពុទ្ធចក្រ ។ ក៏ដូចគ្នានឹងអំពើពុករលួយគ្រប់យ៉ាងរបស់អ្នករដ្ឋការគ្រប់តំណែង ដែលពិភពលោកគ្រប់ប្រទេសកំពុងកំចាត់ ក៏ពុំកើតមានដែរ ព្រោះអនុវត្តតាមធម៌ព្រះពុទ្ធ ក្នុងផ្លូវពុទ្ធចក្រ ។ ដូច្នេះផ្លូវពុទ្ធចក្រទុកដូចជាទីប្រឹក្សា ឬជាប្រទីបដ៏ភ្លឺថ្លាសំរាប់បំភ្លឺផ្លូវអាណាចក្រ ឲ្យធ្វើដំណើរឆ្ពោះទៅរកសុខសន្តិភាពនិងវឌ្ឍនភាពនៃសង្គមខ្មែរ ។ បើប្រទេសកម្ពុជាអនុវត្តបានត្រឹមត្រូវនូវធម៌ព្រះពុទ្ធ នេះអំពើហឹង្សាគ្រប់យ៉ាងរវាងបុគ្គលនិងបុគ្គលក្តី រវាងអ្នកនយោបាយក្តី ដែលកម្ពុជាកំពុងជួបប្រទះនេះនឹងពុំកើតមានឡើយ ។៚